# ពិធីសារ

## ស្ដីពីការផ្លាស់ប្ដូរ សម្ភារៈសច្ចាបន៍ នៃសន្ធិសញ្ញា
## កំណត់ព្រំដែនរដ្ឋ រវាង សាធារណរដ្ឋសង្គមនិយម-
## វៀតណាម និងសាធារណរដ្ឋប្រជាមានិតកម្ពុជា

ភាគីដែលបានចុះហត្ថលេខា នៅខាងក្រោមនេះ :

អនុរដ្ឋមន្ត្រី ក្រសួងការបរទេស នៃសាធារណរដ្ឋសង្គមនិយម វៀតណាម

ហ្វាង ប៊ិច សឺន

និង ឯកអគ្គរដ្ឋទូត វិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ប្រចាំ សាធារណរដ្ឋសង្គមនិយម វៀតណាម .

ទេព ហែន

ថ្ងៃនេះបានផ្លាស់ប្ដូរសំភារៈសច្ចាបន៍របស់សន្ធិសញ្ញាកំណត់ខ្សែព្រំដែនរដ្ឋ រវាងសាធារណរដ្ឋសង្គមនិយមវៀតណាម និង សាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលបានចុះហត្ថលេខានៅ ភ្នំពេញ កាលពីថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៨៥ ហើយត្រូវបានក្រុមប្រឹក្សារដ្ឋ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម អនុម័តសច្ចាបន៍នៅថ្ងៃទី ៣០ ខែ មករា ឆ្នាំ ១៩៨៦ និង រដ្ឋសភា នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា អនុម័តសច្ចាបន៍នៅថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ១៩៨៦ ។

ឯកសារទាំងអស់ នៃសំភារៈសច្ចាបន៍ដែលនិយាយខាងលើនេះ ត្រូវបានភាគីទាំងពីរពិនិត្យ ហើយឃើញថា ត្រឹមត្រូវតាមលក្ខណៈច្បាប់ ។

តាមមាត្រាទី ៥ នៃសន្ធិសញ្ញា សន្ធិសញ្ញានេះនឹងមានប្រសិទ្ធិភាពចាប់តាំងពីថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៨៦ នេះតទៅ ។

ភាគីទាំងពីរ បានព្រមព្រៀង ធ្វើពិធីសារ អនុម័តសច្ចាបន៍ជាពីរច្បាប់ ជាភាសាវៀត-ណាម និងភាសាខ្មែរ ។ ទាំងពីរច្បាប់នេះសុទ្ធតែមានតំលៃស្មើគ្នា ។

ធ្វើនៅ ហាណូយ ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៨៦

| | |
|---|---|
| ហ្វាង ប៊ិច សឺន | ទេព ហែន |
| អនុរដ្ឋមន្ត្រី ក្រសួងការបរទេស | ឯកអគ្គរដ្ឋទូត វិសាមញ្ញនិងពេញ |
| នៃ សាធារណរដ្ឋសង្គមនិយមវៀតណាម | សមត្ថភាពនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា |

LUU·TRỮ